YUNNAN DAILY PRESS GROUP
云南日报报业集团

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNANEXPRESS
english.yunnan.cn

ឆ្នាំទី 24 លេខ 6963 ថ្ងៃសុក្រ ទី 26 ខែកុម្ភៈ ឆ្នាំ 2016


## ខេត្តយូនណានរក្សាបានកំណើនយ៉ាងឆាប់រហ័សក្នុងការវិនិយោគចំពោះបរទេស



របាំស្នាមញញឹមនៃអង្គរ ដែលសម្ដែងនៅខេត្តសៀមរាប ក្រោមការឧបត្ថម្ភដោយក្រុមហ៊ុនបណ្ដាក់ទុនឧស្សាហកម្មវប្បធម៌ខេត្តយូនណាន (Yunnan Cultural Industry Investment Holdings Company) (រូបថត:លោក Yang Zheng)



បណ្ណាការនៅក្នុងទីក្រុងភ្នំពេញដែលកំពុងបណ្ដាក់ទុនដោយក្រុមហ៊ុនគុនមីញ ហ្សិនស៊ី (Kunming Xinzhi Group) (រូបថត:លោក Yang Zheng)

*ដោយ : ដែចិនហ្វា*

ឆ្នាំ២០១៥ សហគ្រាសខេត្តយូនណានរក្សាបាននូវកំណើនយ៉ាងឆាប់រហ័សនៅក្នុងការវិនិយោគចំពោះបរទេស។ ឆ្នាំ២០១៥កន្លងមកនេះ សហគ្រាសវិនិយោគបរទេសរបស់ខេត្តយូនណានបានឡើងដល់ចំនួន៦៣៥ ហើយការវិនិយោគចំពោះបរទេសប្រាកដសរុបមានដល់៥.៧៦០លានដុល្លារអាមេរិក។ ក្នុងឆ្នាំ២០១៥នេះដែរ សហគ្រាសវិនិយោគបរទេសបានបន្ថែមចំនួន១០៣ ការវិនិយោគចំពោះបរទេសសរុបមានដល់ ១.៣៥៤លាន ដុល្លារ ពោលគឺមានការកើនឡើង៣០,៤ភាគរយបើធៀបនឹងឆ្នាំ ២០១៤។

**នៅក្នុងទីផ្សារប្រពៃណីបានរក្សាបាន:រឹងមាំ ហើយនៅក្នុងទីផ្សារថ្មីបានទម្លាយភាពទាល់ច្រកថ្មី:**

ប្រទេសទាំង៥នៃ "អនុតំបន់ទន្លេមេគង្គ" គឺជាទីផ្សារបរទេសសំខាន់ជាងគេរបស់ខេត្តយូនណាន ។ ក្នុងឆ្នាំ ២០១៥ ខេត្តយូនណានបានបង្កើតសហគ្រាសវិនិយោគថ្មីចំនួន៦៧នៅប្រទេសឡាវ, ភូមានិងថៃ ស្មើនឹង៦៥ភាគរយនៃចំនួនសហគ្រាសសរុបដែលត្រូវបង្កើតថ្មីនៅបរទេស ។ ការវិនិយោគនៅប្រទេសទាំង៥នៃ "អនុតំបន់ទន្លេមេគង្គ" មានដល់៧៩៣លានដុល្លារ ស្មើនឹង៥៩,៤ភាគរយនៃការវិនិយោគបរទេសសរុបក្នុងឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ ខេត្តយូនណាននៅបានពន្លឿនល្បឿននៃការពង្រីកទីផ្សារថ្មី ដែលបានបង្កើតសហគ្រាសថ្មីនៅប្រទេសអង់គ្លេស, ឥណ្ឌា,នូវែលសេឡង់ និងកាណាដា។ សព្វថ្ងៃនេះ ខេត្តយូនណានបានដាក់វិនិយោគនៅប្រទេសចំនួន៤៥ ។

**សហគ្រាសរដ្ឋមានការវិនិយោគយ៉ាងស្ថិរភាព ហើយសហគ្រាសឯកជនមានការវិនិយោគគួរឱ្យកត់សម្គាល់:**

ក្នុងឆ្នាំ២០១៥ សហគ្រាសរដ្ឋដូចជាក្រុមការវិនិយោគថាមពលខេត្តយូនណានជាដើមមានការវិនិយោគបរទេសដល់៦៥៥លានដុល្លារ ត្រូវជា៤៩,១ភាគរយនៃការវិនិយោគបរទេសសរុបនៃខេត្តយូនណានក្នុងឆ្នាំ២០១៥។ សហគ្រាសវិនិយោគបរទេសឯកជនក៏មានភាពសកម្មណាស់ ក្នុងសហគ្រាសចំនួនទាំង១០៣ ដែលបានបង្កើតថ្មីនៅខេត្តយូនណានក្នុងឆ្នាំ២០១៥ មានសហគ្រាសចំនួន៨៩ គឺជាសហគ្រាសឯកជន មានការវិនិយោគបរទេសដល់៦៧៩លានដុល្លារ ត្រូវជា៥០.៩ភាគរយនៃការវិនិយោគបរទេសសរុបរបស់ខេត្តយូនណានក្នុងឆ្នាំ២០១៥ ។

**ប្រភេទនៃឧស្សាហកម្មមានភាពពិពិធវិស័យនៃការវិនិយោគត្រូវបានបន្តពង្រីក:**

ក្នុងឆ្នាំ២០១៥ ខេត្តយូនណានបានដាក់វិនិយោគនៅឧស្សាហកម្មប្រភេទ៩ជាសំខាន់ ។ ប្រភេទនៃឧស្សាហកម្មដែលត្រូវវិនិយោគមានភាពពិពិធណាស់ ដូចជាផលិតកម្មរោងចក្រកម្រិតស្ដង់ដារ ឧស្សាហកម្ម ឱសថ និងសេវាកម្មបែបថ្មី ដូចជា ឧស្សាហកម្មការពារបរិស្ថានឧស្សាហកម្មអភិបាលកិច្ចបរិស្ថានពាណិជ្ជកម្ម តាមអេឡិចត្រូនិក និងឧស្សាហកម្ម វប្បធម៌ជាដើមត្រូវបានពង្រីកយ៉ាង ខ្លាំង៕

## លោកចាំង លូចឺ អ្នកទីក្រុងឈាងដាវដែលរកស៊ីនៅកម្ពុជា

*ដោយ:ដែចិនហ្វា*

ជិះម៉ូតូធ្វើដំណើរឆ្លងកាត់ព្រៃត្រូពិច ជិះទូកនេសាទទៅកម្សាន្តលើកោះ គេងលើអង្រឹងរវាងដើមឈើ រូបភាពទាំងនេះ គឺពិបាកស្រមៃសម្រាប់មនុស្សធម្មតាចិន ប៉ុន្តែសម្រាប់លោកចាំង លូចឺ នាយកនៃផ្នែកកិច្ចការបរទេសនៃក្រុមហ៊ុន ZHONG QI HOLDING GROUP ដែលរកស៊ីនិងរស់នៅក្នុងប្រទេសកម្ពុជាជាយូរហើយនោះ គឺជាការធម្មតាទៅហើយ ។

លោកចាំង លូចឺ មកពីទីក្រុងឈាងដាវខេត្តសានដុងប្រទេសចិន។ ផ្លូវសហគ្រិននៅប្រទេសកម្ពុជារបស់លោកក៏ដូចគ្នានឹងផ្លូវភ្នំបត់បែនមួយ។ ធ្វើជាអនុប្រធានក្រុមហ៊ុន និងនាយកនៃផ្នែកកិច្ចការបរទេសនៃក្រុមហ៊ុន ZHONG QI HOLDING GROUP លោកចាំង លូចឺ ពិតមែនជាអ្នកមានជោគជ័យម្នាក់ ។ ឆ្នាំ២០១៣ ស្រេចតាមយុទ្ធសាស្ត្រនៃក្រុមហ៊ុន លោកបានលះបង់បរិយាកាសការិយាល័យល្អក្នុងស្រុកមកដល់ស្រុកខ្មែរដោយខ្លួនឯងដើម្បីមកទទួលខុសត្រូវលើកម្មវិធីវិនិយោគជាច្រើននៅប្រទេសកម្ពុជា។

ពេលដំបូង លក្ខខណ្ឌការងារពិតជាពិបាកណាស់ ជាពិសេសកម្មវិធីវិនិយោគចំពោះព្រៃត្រូពិចទិសពាយ័ព្យកម្ពុជា។ លោកត្រូវការពុះពារការលំបាកយ៉ាងធំណាស់ក្នុងកិច្ចការសិក្សាក្នុងព្រៃត្រូពិចគ្រប់លើក។ ពេលខ្លះលោកត្រូវរស់នៅក្នុងព្រៃឈើច្រើនថ្ងៃជាមួយនឹងមិត្តរួមការងារ នៅពេលយប់សំឡេងរបស់សត្វដំរីជ្រូកព្រៃ និងខ្លារខិនតែងតែធ្វើឱ្យគេខ្លាចញាក់ញ័រ។ គ្មានគ្រែ ពួកគេក៏ដាក់អង្រឹងចងជាប់រវាងដើមឈើពីរ ហើយគេងលើអង្រឹងរហូតដល់ព្រឹក។

ក្រៅពីត្រូវធ្វើការក្នុងព្រៃ ឈើម្ដងម្កាល ភារកិច្ចសំខាន់មួយទៀត របស់លោកចាំង លូចឺ គឺជិះទូកទៅរកកោះសមល្មមនៅក្នុងសមុទ្រដើម្បីជ្រើសរើស កោះសម្រាប់អភិវឌ្ឍន៍ជាកន្លែងទេសចរណ៍។ ជាមធ្យមលោកត្រូវទៅ រកស្វែងកោះបីថ្ងៃម្ដង។ ម្ដងត្រូវការ ច្រើនម៉ោង។ ជួនកាលប្រទះព្យុះ ។ លោកនិងមិត្តរួមការងារតែងតែត្រូវ ភ្លៀងទទឹកជោក ។

ក្នុងអំឡុងពេលដែលលោកចាំង លូចឺ ធ្វើការនៅក្នុងប្រទេសកម្ពុជា ទោះបីមានការលំបាកខ្លាំងណាស់ ប៉ុន្តែលោកនៅប្រមូលផលជាច្រើនទៀត ហើយសំខាន់បានចំណងមិត្តភាពជាច្រើន ។ ភាពស្មោះត្រង់របស់លោកចាំង លូចឺ ធ្វើឱ្យលោក និងជនខ្មែរជាច្រើនបានក្លាយជាមិត្តល្អណាស់ ។

លោកបរិយាយថា យោងតាមផែនការនៃក្រុមហ៊ុន កម្មវិធីកសាងធំៗខ្លះត្រូវការរយៈពេលប៉ុន្មានឆ្នាំរហូតជាង១០ឆ្នាំ ។ ទោះបីថាអាចប្ដូរកន្លែងការងារទៅប្រទេសចិនវិញក្នុងរាល់៣ឆ្នាំ ប៉ុន្តែធ្វើជាអ្នកទទួលខុសត្រូវនៅប្រទេសកម្ពុជា លោកចង់ធ្វើការនៅស្រុកខ្មែរជារហូត ។ ឆ្នាំនេះ លោកនឹងទទួលភរិយាមករស់នៅក្នុងកម្ពុជា អ៊ីចឹងលោកក៏គ្មានការណាគួរឱ្យព្រួយ ហើយលោកនឹងខំប្រឹងធ្វើការនៅប្រទេសកម្ពុជា ដើម្បីមានជោគជ័យកាន់តែច្រើនទៀត ៕

## ក្រុមហ៊ុនជ្រលងដំរីព្រៃចុះហត្ថលេខាលើអនុស្សរណៈមួយអំពីកម្មវិធី "ដំរីដង្ហែក្បួន"

*ដោយ : ដែចិនហ្វា*

ដំរីអាស៊ីគួរឱ្យស្រឡាញ់មួយក្បាលបានមកដល់វេទិកា ហើយយករូបភាពមួយដោយច្រមុះវា ហើយប្រគល់ឱ្យអ្នកទទួលខុសត្រូវនៃក្រុមហ៊ុន "ដំរីដង្ហែក្បួន" អន្តរជាតិ ។ ករណីដ៏អស្ចារ្យនេះបានកើតឡើងក្នុងពិធីចុះហត្ថលេខានៃអនុស្សរណៈលើគម្រោងដំរីដង្ហែក្បួននៅជ្រលងដំរីព្រៃរដ្ឋស៊ីស្វាំងប៉ាន់ណា ខេត្តយូនណាន កាលពីថ្ងៃទី១៦ ខែកុម្ភៈនេះ ។

តាមព័ត៌មានថា "ដំរីដង្ហែក្បួន" គឺជាសកម្មភាពមានផលប្រយោជន៍សាធារណៈមួយដែលដំណើរការដោយអង្គការមួយនៃប្រទេសហូឡង់ដើម្បីការពារ និងជួយសង្គ្រោះដំរីអាស៊ី ។ សកម្មភាពនេះបង្កើតឡើងដោយសារដំរីប្រទេសថៃមួយក្បាលឈ្មោះម៉ូសា ដែលបាក់ជើងមួយដោយសារគ្រាប់មីន ។ កម្មវិធីនេះយកផលិតផលអំពីដំរីជាវេទិកា ។ យកការលក់ទំនិញជាវិធីអាជីវកម្មសំខាន់ ហើយយកការការពារដំរីជាគោលដៅភាគ២០ភាគរយនៃចំណេញនិងជូនអំណោយដល់អង្គការការពារដំរីនៅគ្រប់ប្រទេស ។ ចាប់តាំងពីឆ្នាំ២០០៧រៀងមកកម្មវិធីនេះបានប្រារព្ធចំនួន១៦ដង ហើយបានធ្វើឡើងនៅក្នុងទីក្រុងជិតចំនួន២០នៃប្រទេសចំនួន១១ ។

ការចុះហត្ថលេខាលើកនេះ បានធ្វើឱ្យកម្មវិធី "ដំរីដង្ហែក្បួន" ក្លាយជាកម្មវិធីផលប្រយោជន៍សាធារណៈតែមួយគត់នៅក្នុងប្រទេសចិន ដែលយកការការពារដំរីជាគោលដៅសំខាន់ ។ តាមដំណឹងថា សកម្មភាពនេះនឹងប្រព្រឹត្តក្នុងឆ្នាំនេះ ដល់ពេលនោះនឹងមានសិល្បករ និងអ្នកវិទ្យាសាស្ត្រមកចូលរួម ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនចំពោះការការពារដំរីព្រៃ ៕



ក្រុមហ៊ុនជ្រលងដំរីព្រៃចុះហត្ថលេខាលើអនុស្សរណៈមួយអំពីកម្មវិធី "ដំរីដង្ហែក្បួន"

## ជញ្ជាំងសប្បុរសត្រូវបាន បង្កើតឡើងក្នុងទីក្រុងគុនមីញ

*ដោយ : ជួឈី*

"បើអ្នកមិនត្រូវការសុំចៀសចេញ។ បើអ្នកត្រូវការសូមយកវាទៅចុះ"។

ដើមឆ្នាំនេះ ជញ្ជាំងសប្បុរសជាច្រើនបានលេចមុខក្នុងទីក្រុងជាច្រើននៃប្រទេសចិន ។ ឥឡូវនេះជញ្ជាំងសប្បុរសនេះក៏ត្រូវបានបង្កើតឡើងក្នុងទីក្រុងគុនមីញ ។ មនុស្សនានាបានព្យួរសម្លៀកបំពាក់លើជញ្ជាំងនេះផ្ដល់ឱ្យមនុស្សដែលត្រូវការសម្លៀកបំពាក់ទាំងនេះ ។ បើត្រូវការពិតមែន ពួកគេអាចយកសម្លៀកបំពាក់ទាំងនេះទៅដោយមិនគិតលុយ ។

ប៉ុន្មានថ្ងៃនេះ អ្នកយកព័ត៌មានយើងបានឃើញជញ្ជាំងសប្បុរសបែបនេះនៅផ្លូវដុងហ្វឹង និងផ្លូវមឹងថុង ។ នៅលើជញ្ជាំងបានព្យួរសម្លៀកបំពាក់គ្រប់ប្រភេទដូចជាអាវរោម អាវយឺតសម្លៀកបំពាក់រដូវរងា និងស្បែកជើងជាដើម ។

មីងហ្វ៊ូ ដែលជាអ្នកស្រុកម្នាក់បានប្រាប់យើងថា "មនុស្សណាក៏ដោយឱ្យតែត្រូវការសម្លៀកបំពាក់ទាំងនេះអាចយកទៅដោយមិនគិតលុយ" ។ មីងនិយាយបណ្ដើររៀបចំសម្លៀកបំពាក់លើជញ្ជាំងបណ្ដើរ ។ ការធ្វើសប្បុរសបែបនេះនឹងការពារសេចក្ដីថ្លៃថ្នូររបស់មនុស្សដែលមានតម្រូវការ ។




ជញ្ជាំងសប្បុរសត្រូវបានបង្កើតឡើងក្នុងទីក្រុងគុនមីញ (រូបថតលោកជួឈី)

តាមព័ត៌មានថា ដើមឆ្នាំនេះ នៅទីក្រុងឆឹងឌូ ទីក្រុងហឺហ្វៃជាដើម បានកសាងជញ្ជាំងបែបនេះជាដំបូង ។ ចំណែកទីក្រុងគុនមីញការជូនអំណោយសម្លៀកបំពាក់គឺមិនមែនលើកទី១ទេ ។ ឆ្នាំកន្លងទៅនៅកន្លែងនៃទីក្រុងគុនមីញខ្លះក៏មានធុងសប្បុរស ហើយមនុស្សចិត្តសប្បុរសដាក់សម្លៀកបំពាក់ក្នុងធុងនីមួយៗ ហើយជូនធុងទាំងនេះដល់កន្លែងមានតម្រូវការ ។

"ទោះបីធុងសប្បុរសឬជញ្ជាំងសប្បុរសទាំងជាការធ្វើតេស្តមួយបែបចំពោះអ្នកមានចិត្តសប្បុរស និងមនុស្សដែលមានតម្រូវការ" ។ លោកការជានយូន លេខាធិការសង្កាត់មឹងថុងបានបញ្ជាក់ ។

លោកនិយាយទៀតថា សង្កាត់មឹងថុង មានកំណត់ដូចតទៅ ទី១-សម្លៀកបំពាក់ ដែលព្យួរលើជញ្ជាំងយ៉ាងហោចត្រូវជាសម្លៀកបំពាក់ថ្មី៧០ភាគរយ ហើយសម្លៀកបំពាក់ទាំងនេះត្រូវសម្អាតឱ្យស្អាតជាចាំបាច់ ។ ទី២-ហាមឃាត់ព្យួរខោអាវក្នុង ។ សង្កាត់មឹងថុងនឹងចាត់ចែងបុគ្គលិកទៅត្រួតពិនិត្យសម្លៀកបំពាក់ទាំងលើជញ្ជាំងឱ្យតែរកឃើញសម្លៀកបំពាក់ចាស់ៗ និងខោអាវក្នុងនឹងបោះបង់តែម្ដង ។ "យើងធ្វើយ៉ាងនេះគឺដើម្បីធានាមនុស្សដែលមានតម្រូវការអាចស្លៀកពាក់សម្លៀកបំពាក់ថ្មី និងស្អាត" ៕